# គណបក្ស សម រង្ស៊ី

## SAM RAINSY PARTY

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

SRP NORWAY

គ្រីស្ទានសាន់ ថ្ងៃទី ១៨ ខែសីហា ឆ្នាំ២០០៧

## សេចក្តីថ្លែងការណ៍

សាខាគណបក្ស សម រង្ស៊ី ប្រចាំប្រទេសន័រវេស្ស សូមគាំទ្រយ៉ាងពេញទំហឹងចំពោះបាតុកម្មអហិង្សា ដែលរៀបចំដោយសហព័ន្ធ អង្គការ សមាគម និងព្រះសង្ឃ ព្រមទាំងបងប្អូនខ្មែរដើមកំណើតជាខ្មែរកម្ពុជាក្រោម នៅបណ្តាប្រទេសនានាក្នុងពិភពលោក ដើម្បីទាមទារសិទ្ធិសេរីភាពរបស់បងប្អូន ដែលជាសិទ្ធិមូលដ្ឋានរបស់មនុស្សគ្រប់រូប ត្រូវបានចែងនៅក្នុងកត្តិកាសញ្ញា-អនុសញ្ញាអន្តរជាតិ ដែលបច្ចុប្បន្នត្រូវបាននិងកំពុងរំលោភយ៉ាងកំរោលពីសំណាក់រដ្ឋាភិបាលខ្មែរ និងរដ្ឋាភិបាលវៀតណាម ។

ជាក់ស្តែងសម្តេចព្រះសង្ឃរាជ **ទេព វង្ស** សម្តេចព្រះមហាសុមេធាធិបតី **នន្ទ ង៉ែត** និងរដ្ឋាភិបាលខ្មែរ បានសមគំនិតគ្នាចាប់ផ្សឹកអតីតព្រះគ្រូចៅអធិការវត្តភ្នំដិន **ព្រះនាម ទឹម សាខន** ក្រោមបទចោទប្រកាន់ដ៏អយុត្តិធម៌ ហើយបញ្ជូនយ៉ាងតក់ក្រហល់អោយទៅរដ្ឋាភិបាលវៀតណាមដាក់ពន្ធនាគារ គឺជាទង្វើប្រាសចាកមាគ៌ាព្រះពុទ្ធសាសនា រំលោភច្បាប់ និងរំលោភរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទាំងនេះគឺជាការបញ្ជាក់អោយមជ្ឈដ្ឋានជាតិ និងអន្តរជាតិមើលឃើញកាន់តែច្បាស់ថា រដ្ឋាភិបាលខ្មែរ និង រដ្ឋាភិបាលវៀតណាម ព្រមទាំងសម្តេចសង្ឃទាំងពីរអង្គ បានរៀបចំផែនការរួចជាស្រេច ដើម្បីធ្វើទុក្ខបុកម្នេញគ្រប់បែបយ៉ាងទៅលើព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមយ៉ាងពិតប្រាកដ។

សាខាគណបក្ស សម រង្ស៊ី ប្រទេសន័រវេស្ស សូមថ្កោលទោសយ៉ាងដាច់អហង្កា ចំពោះរដ្ឋាភិបាលខ្មែរ និងរដ្ឋាភិបាលវៀតណាម ព្រមទាំងសម្តេចព្រះសង្ឃទាំងពីរអង្គ ដែលរំលោភសិទ្ធិសេរីភាព ជំនឿសាសនា របស់ព្រះសង្ឃនិងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម។

តាមរយៈបាតុកម្មអហិង្សានាពេលនេះ សាខាគណបក្ស សម រង្ស៊ី ប្រចាំប្រទេសន័រវេស្ស សូមអំពាវនាវយ៉ាងទទូចដល់សហគមន៍ជាតិ-អន្តរជាតិ សូមដាក់សម្ពាធអោយធ្ងន់ធ្ងរចំពោះ រដ្ឋាភិបាលខ្មែរ និងរដ្ឋាភិបាលវៀតណាម ព្រមទាំងសម្តេចព្រះសង្ឃរាជ សម្តេចព្រះមហាសុមេធាធិបតី អោយបញ្ឈប់ជាបន្ទាន់ នូវការគំរាមកំហែង សម្លាប់ និងបំបិតសិទ្ធិសេរីភាពគ្រប់យ៉ាងរបស់ព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមទាំងក្នុងនិងក្រៅប្រទេស។

**គណបក្ស សម រង្ស៊ី ប្រចាំប្រទេសន័រវេស្ស**

**ប្រធាន**

**ឆាំ ឆានី**

ផ្ទះលេខ ៣២ បេ ផ្លូវប៊ូហូសហ៊ីយ៉ា ប្រអប់សំបុត្រ ៤៦៣៤ ក្រុងគ្រីស្ទានសាន់ ប្រទេសន័រវែស្ស (Buhusheia 32 B 4634 Kristiansand, Norway)
Tel: +47-90-248-713 / +47-94-803-398 / +47-99-489-347 / Email: srpnorway@yahoo.com